ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សុន្ទរកថាស្វាគមន៍**

**ឯកឧត្តម បណ្ឌិត ហង់ ជួន ណារ៉ុន**

ប្រធានក្រុមប្រឹក្សាភិបាលវិទ្យាស្ថានបណ្តុះបណ្តាល និងអភិវឌ្ឍន៍កម្ពុជា

អនុប្រធានប្រចាំការឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

អគ្គលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*- សម្តេចនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត*

*- ឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ លោក លោកស្រី ជាទីគោរពរាប់អាន!*

ក្នុងឋានៈជាប្រធានក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានបណ្តុះបណ្តាល និងអភិវឌ្ឍន៍កម្ពុជា ខ្ញុំមានសេចក្តីសោមនស្សរីករាយ សូមស្វាគមន៍ ចំពោះវត្តមាន សម្តេច ឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ លោក លោកស្រី ដែលបានចូលរួមក្នុង «សន្និសីទចក្ខុវិស័យកម្ពុជា» ដែលរៀបចំឡើងរួមគ្នារវាងវិទ្យាស្ថានបណ្តុះបណ្តាល និងអភិវឌ្ឍន៍កម្ពុជា និងធនាគារ ***អេអ៊ិនហ្សិត រ៉ូយ៉ាល់*** ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់ និងថ្លែងសុន្ទរកថាគន្លឹះពី សំណាក់សម្តេចអគ្គសេនាបតីតេជោ **ហ៊ុន សែន** ។ យើងខ្ញុំសូមសម្តែងនូវកតញ្ញុតាធមិដ៏ជ្រាលជ្រៅចំពោះសម្តេច ដែលបន្តគាំទ្រសន្និសីទចក្ខុវិស័យកម្ពុជាប្រចាំឆ្នាំ ព្រមទាំងផ្តល់តម្លៃចំពោះការងារស្រាវជ្រាវអភិវឌ្ឍន៍គោលនយោបាយឯករាជ្យរបស់វិទ្យាស្ថានបណ្តុះបណ្តាល និងអភិវឌ្ឍន៍កម្ពុជា ។

នេះជាសន្និសីទចក្ខុវិស័យកម្ពុជា ដែលរៀបចំរួមគ្នាដោយ វិទ្យាស្ថានបណ្តុះបណ្តាល និងអភិវឌ្ឍន៍កម្ពុជា និង ធនាគារ ***អេអ៊ិនហ្សិត រ៉ូយ៉ាល់*** ដែលប្រធានបទប្រចាំឆ្នាំនេះគឺ «កម្ពុជាវិបត្តិពិភពលោក ÷ ផលប៉ះពាល់ គោលនយោបាយ និង សកម្មភាពឆ្លើយតប »។ ជាថ្មីម្តងទៀតសន្និសីទនេះបានប្រមូលផ្តុំ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

មនុស្សសំខាន់ពីសាធារណៈជននៅកម្ពុជា ដើម្បីពិចារណាពីសមិទ្ធិផល ផ្លាស់ប្តូរគំនិត និងពិភាក្សាពីយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍ និងវិបុលភាពក្នុងពេលអនាគត ក៏ដូចជាបង្កើតអនុសាសន៍សកម្មភាពគោលនយោបាយជាក់លាក់ ក្នុងកាលៈទេសៈដ៏លំបាកនៃវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសកលលោក ។

សម្តេចអគ្គសេនាបតីតេជោ **ហ៊ុន សែន** ឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ លោក លោកស្រី ជាថ្មីម្តងទៀត សន្និសីទចក្ខុវិស័យកម្ពុជា ប្រារព្ធឡើងក្រោមទិសស្លោក «អនាគតក្នុងដៃយើងទាំងអស់គ្នា» ដោយសារវាបង្កប់កន្លាសត្យានុម័តដែលថា ជោគជ័យនៃការអភិវឌ្ឍន៍ និងការចែករំលែកវិបុលភាពនៃអនាគតកម្ពុជា អាស្រ័យទៅលើ បញ្ញាញាណ ការប្តេជ្ញាចិត្ត និងភាពឧស្សាហ៍ព្យាយាមនៃប្រជាជនយើងទាំងអស់ ក្នុងការក្តាប់យកឱកាស និងជំនះបញ្ហាប្រឈមមុខដែលប្រជាជនកម្ពុជាកំពុងជួបប្រទះ ។ កម្មវិធីពេញមួយថ្ងៃនេះ នឹងពិភាក្សាលើបញ្ហាសំខាន់ៗជាច្រើន ដែលនឹងកំណត់អនាគតកម្ពុជា ក្នុងបរិបទនៃវិបត្តិសេដ្ឋកិច្ចពិភពលោក និងផលប៉ះពាល់មកលើតំបន់ និងកម្ពុជា ។ តើយើងត្រូវអភិវឌ្ឍន៍ធនធានមនុស្សកម្ពុជាដូចម្តេចដើម្បីកសាងកម្លាំងពលកម្មជំនាញ ? តើត្រូវគ្រប់គ្រងវិស័យសំខាន់ៗ ដូចជា កសិកម្ម និងការអភិវឌ្ឍជនបទ ទេសចរណ៍ កម្មន្តសាល អចលនវត្ថុ និងសំណង់ ដូចម្តេច ឆ្លងកាត់វិបត្តិដើម្បីចូលរួមកសាងកំណើន វិបុលភាព និងការកាត់បន្ថយភាពក្រីក្រ ក្នុងពេលអនាគត ? និងជាចុងក្រោយ តើមានសកម្មភាពគោលនយោបាយអាទិភាព របស់រដ្ឋាភិបាល វិស័យឯកជន ដៃគូរអភិវឌ្ឍន៍កម្ពុជា សហគមន៍ស្រាវជ្រាវ ដែលត្រូវធ្វើការរួមគ្នាដើម្បីអនាគតកម្ពុជា ?

ដោយឡែកនាឱកាសព្រឹកនេះ ដើម្បីផ្តល់ជាគំនិត ជម្រុញគំនិត និងផ្តល់ជាបរិការណ៍សម្រាប់កិច្ចពិភាក្សារបស់យើង យើងមានបុព្វសិទ្ធិ និងកិត្តិយសដ៏ខ្ពង់ខ្ពស់ ដែលទទួលបានការចូលរួមរបស់សម្តេចអគ្គសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។ ក្នុងឱកាសនេះខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ និងសោមនស្ស ក្នុងនាមវិទ្យាស្ថានបណ្តុះបណ្តាល និងអភិវឌ្ឍន៍កម្ពុជា និង ធនាគារ ***អេអ៊ិនហ្សិត រ៉ូយ៉ាល់*** សូមគោរពអញ្ជើញសម្តេចតេជោ ថ្លែងសុន្ទរកថាគន្លឹះ ក្នុងសន្និសីទចក្ខុវិស័យកម្ពុជា ២០០៩ ។

សូមអរគុណ!